# ស្ថានភាពប្រព័ន្ធអេកូឡូស៊ី

# តំបន់ជីវចម្រុះសំខាន់ៗនៅតំបន់ឥណ្ឌូ ភូមា

## បច្ចុប្បន្នភាព ២០២០

**សំណេរចុងក្រោយខែកញ្ញា ឆ្នាំ២០២០**

## មូលន័យសង្ខេប

មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (CEPF)ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីការពារតំបន់ដែលរងការគម្រាមកំហែងនិងសំបូរទៅដោយធនធានជីវចម្រុះច្រើនបំផុតនៅលើភពផែនដី (Biodiversity hotspots)។ មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីសំខាន់ៗនេះ គឺជាកិច្ចផ្តួចផ្តើមរួមមួយរវាងទីភ្នាក់ងារអភិវឌ្ឍន៍បារាំង អង្គការអភិរក្សអន្តរជាតិ សហភាពអឺរ៉ុប មូលនិធិបរិស្ថានពិភពលោក រដ្ឋាភិបាលជប៉ុន និងធនាគារពិភពលោក។

ទិសដៅជាសារវន្តនៃមូលនិធិ CEPF នេះ គឺដើម្បីធានាឲ្យមានការចូលរួមពីបណ្តាសង្គមស៊ីវិល មានដូចជាក្រុមសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល វិទ្យាស្ថានអប់រំ និងសហគ្រាសឯកជន ក្នុងកិច្ចការអភិរក្សជីវចម្រុះក្នុងតំបន់ដែលសំបូរទៅដោយធនធានជីវចម្រុះ (តំបន់ហាតស្ពត)។ ដើម្បីធានាបាននូវភាពជោគជ័យរបស់ពួកគេ កិច្ចប្រឹងប្រែងអភិរក្ស ត្រូវតែបំពេញបន្ថែមលើយុទ្ធសាស្ត្រ និងកម្មវិធីដែលមានស្រាប់របស់រដ្ឋាភិបាល និងម្ចាស់ជំនួយលើការងារអភិរក្សផ្សេងទៀត។ មូលនិធិ (CEPF) នេះ ជំរុញឲ្យមានសម្ព័ន្ធភាពធ្វើការជាមួយគ្នាក្នុងចំណោម ក្រុមផ្សេងៗគ្នាដោយរួមបញ្ចូលនូវសមត្ថភាពខ្លាំងពិសេសនិងការកាត់បន្ថយនូវភាពស្ទួនគ្នាដដែលៗនៃកិច្ចប្រឹងប្រែង ដើម្បីឲ្យមានអភិក្រមមួយមានការសម្របសម្រួលនិងទូលំទូលាយ។ អភិក្រមមួយរបស់មូលនិធិ CEPF គឺការរៀបចំ" **ស្ថានភាពប្រព័ន្ធអេកូឡូស៊ី** Ecosystem Profile"៖ ដែលជាឯកសារយុទ្ធសាស្ត្ររួមមួយ ដោយ មានការប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធជាច្រើន ដែលបានដាក់ចេញនូវយុទ្ធសាស្ត្រវិនិយោគរយៈពេល៥ឆ្នាំ ដោយមានការវិភាគយ៉ាងលម្អិតពីស្ថានភាពប្រព័ន្ធអេកូឡូស៊ី។

ឯកសារយុទ្ធសាស្ត្រនេះបង្ហាញពីស្ថានភាពប្រព័ន្ធអេកូឡូស៊ីនៅតំបន់ហាតស្ពតឥណ្ឌូភូមានៃប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ាថៃនិងវៀតណាម រួមទាំងផ្នែកខ្លះនៃភាគខាងត្បូងប្រទេសចិន ដោយមិនរាប់ចូលតំបន់ឆ្នេរសមុទ្រឡើយ។ ដោយមានវត្តមានប្រភេទរុក្ខជាតិនិងសត្វជាច្រើនតែក្នុងតំបន់និងទីជម្រកធម្មជាតិដែលនៅសេសសល់មិនច្រើនប៉ុន្មាននោះ តំបន់ហាតស្ពតឥណ្ឌូ-ភូមាជាប់ក្នុងចំណាត់ថ្នាក់តំបន់ហាតស្ពតកំពូលទាំង១០ ដោយសារភាពអស្ចារ្យរបស់វាដែលមិនអាចមានអ្វីមកជំនួសបាននិងជាតំបន់ហាតស្ពតកំពូលទាំង៥ ដែលទទួលរងនូវការគម្រាមកំហែង។

តំបន់ហាតស្ពតឥណ្ឌូ - ភូមាមានមនុស្សរស់នៅច្រើនជាងតំបន់ហាតស្ពតដទៃៗទៀតហើយប្រព័ន្ធអេកូឡូស៊ីធម្មជាតិដែលនៅសេសសល់ក្នុងតំបន់ហាតស្ពតនោះ មានការបាត់បង់យ៉ាងខ្លាំង ដោយសារការបាត់បង់ទីជម្រក ការរិចរេល និងខូចខាតទ្រង់ទ្រាយជម្រកធម្មជាតិ និងការធ្វើអាជីវកម្មធនធានធម្មជាតិហួសកម្រិត។

## បច្ចុប្បន្នភាពស្ថានភាពប្រព័ន្ធអេកូឡូស៊ី

មូលនិធិ CEPF បានផ្តល់ជំនួយឥតសំណងដល់បណ្តាក្រុមអង្គការសង្គមស៊ីវិលក្នុងតំបន់ហាតស្ពត ឥណ្ឌូ - ភូមានេះតាំងពីខែកក្កដា ឆ្នាំ២០០៨ មកម្លេះ ដែលបានចង្អុលបង្ហាញដោយឯកសារស្ថានភាពប្រព័ន្ធអេកូឡូស៊ីរៀបចំ

ឡើងក្នុងឆ្នាំ ២០០៣ និងត្រូវបានធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ ២០១១ ដោយមាន ការពិគ្រោះយោបល់ពីអ្នកភាគីពាក់ព័ន្ធយ៉ាងទូលំទូលាយ។ រហូតមកដល់បច្ចុប្បន្ននេះ មានគម្រោងសរុបចំនួន ៣១៥ ដែលត្រូវបានផ្តល់មូលនិធិដោយ CEPF នៅក្នុងតំបន់ហាតស្ពតឥណ្ឌូភូមា។

មានការប្រែប្រួលច្រើនណាស់ក្នុងរយៈពេល៩ឆ្នាំចាប់តាំងពីឯកសារស្ថានភាពអេកូឡូស៊ីត្រូវបានធ្វើបច្ចុប្បន្នភាពចុងក្រោយនៅឆ្នាំ២០១១។ មានការប្រែប្រួលមួយចំនួនទាក់ទងនឹងការយល់ដឹងអំពីស្ថានភាពជីវៈចម្រុះដែលមានសារៈសំខាន់ជាសាកល រួមទាំងប្រភេទសត្វដែលរងការគម្រាមកំហែងជាសកលនិងតំបន់ជីវចម្រុះសំខាន់ៗ។ មានការប្រែប្រួលនៃធម្មជាតិនិងសារៈសំខាន់នៃការគម្រាមកំហែងដល់ជីវចម្រុះនិងមូលហេតុជាឫសគល់របស់វា។ ជាពិសេស ការកាប់បំផ្លាញព្រៃឈើមានអត្រាខ្ពស់ ដោយអត្រាបាត់បង់គម្របព្រៃក្នុងឆ្នាំចាប់ពី ២០១០-២០១៩ ស្ទើរតែមានចំនួន២ដងបើធៀបនឹងឆ្នាំ ២០០០-២០១០។ ការបាត់បង់ទីជម្រកនិងការធ្វើអាជីវកម្មហួសកម្រិតបានធ្វើឲ្យមានការគម្រាមកំហែងកាន់តែខ្លាំងឡើងទៅលើចំនួនរុក្ខជាតិនិងសត្វ ដែលជាប្រភេទរងការគម្រាមកំហែងជាសាកលក្នុងបញ្ជីក្រហមរបស់អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ IUCN កើនឡើងជាង៧០ភាគរយក្នុងចន្លោះឆ្នាំ ២០១១ និង ២០២០ ។ ទន្ទឹមនឹងនេះដែរ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដែលគេសង្កេត ឃើញមាននៅក្នុងតំបន់ហាតស្ពតនេះ ដូចជា ការកើនឡើងនូវសីតុណ្ហភាពជាមធ្យម; របបទឹកភ្លៀងបានផ្លាស់ប្តូរ; កម្រិតទឹកសមុទ្របានចាប់ផ្តើមកើនឡើង; ហើយការកើតមានឡើងជាញឹកញាប់នូវព្រឹត្តិការណ៍អាកាសធាតុកំណាចផ្សេងៗទៀត។

និន្នាការនៃការបាត់បង់ទីជម្រកដ៏ឆាប់រហ័ស ការធ្វើអាជីវកម្មហួសកម្រិតនិងការប្រែប្រួលអាកាសធាតុបានបង្កើតឱ្យមានវិបត្តិផ្នែកប្រព័ន្ធអេកូឡូស៊ី ដែលផ្សារភ្ជាប់គ្នាទៅនឹងធនធានជីវៈចម្រុះ សុខភាពមនុស្សនិងការអភិវឌ្ឍសេដ្ឋកិច្ច។

ក្នុងរយៈពេល៩ឆ្នាំចុងក្រោយនេះ ក៏ឃើញមានការផ្លាស់ប្តូរនូវបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិលដែលធ្វើការក្នុងតំបន់ហាតស្ពតផងដែរ។ លំហានយោបាយដែលមានសម្រាប់អង្គការសង្គមស៊ីវិលនៅតែមានកម្រិតនៅឡើយ ហើយម្ចាស់ជំនួយអន្តរជាតិមួយចំនួនដែលជាប្រភពគាំទ្រដ៏សំខាន់ដល់អង្គការសង្គមស៊ីវិលនោះក៏បានចប់កម្មវិធីផ្តល់ជំនួយឥតសំណងរបស់ពួកគេនៅក្នុងតំបន់ផងដែរ។ មានការបង្ហាញភស្តុតាងអំពីប្រសិទ្ធភាពនៃអភិក្រមអភិរក្សផ្សេងៗគ្នាដែលត្រូវបានសាកល្បងនៅក្នុងតំបន់ហាតស្ពត ចាប់តាំងពីការលេចចេញនូវចលនានៃការអភិរក្សបែបទំនើបនៅដើមទសវត្សឆ្នាំ១៩៩០មកម្លេះ។ អភិក្រមមួយចំនួនដែលមានឥទ្ធិពលវិជ្ជមានទៅលើជីវៈចម្រុះនិងសុខុមាលភាពមនុស្សត្រូវបានបង្ហាញនៅក្នុងបរិបទជាក់លាក់នៅមូលដ្ឋាន ទោះបីអភិក្រមទាំងនេះនៅមានកម្រិត បើធៀបនឹងកម្រិតនៃការគម្រាមកំហែងចំពោះជីវចម្រុះនៅក្នុងតំបន់ហាតស្ពត។

ដោយមានការផ្លាស់ប្តូរជាច្រើន ចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពលើស្ថានភាពប្រពន្ធ័អេកូឡូស៊ីនិងយុទ្ធសាស្ត្រវិនិយោគសម្រាប់ការវិនិយោគ CEPF នៅដំណាក់កាលបន្ទាប់ក្នុងតំបន់ហាតស្ពតនេះ។ ការធ្វើបច្ចុប្បន្ននេះ ធ្វើឡើង

ដោយមានការចូលរួមជាមូលដ្ឋានមួយដែលម្ចាស់ជំនួយចាប់អារម្មណ៍ ក្នុងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងអភិរក្សដោយអង្គការសង្គមស៊ីវិលដែលអាចបង្កើតគោលដៅនិងយុទ្ធសាស្ត្ររួមគ្នា ដែលឆ្លើយតបទៅនឹងអាទិភាពខ្ពស់បំផុតឱកាស និងបន្សុីជាមួយនឹងការវិនិយោគដែលមានស្រាប់ដោយរដ្ឋាភិបាលនិងម្ចាស់ជំនួយផ្សេងទៀត។

ឯកសារស្ថានភាពប្រព័ន្ធអេកូឡូស៊ីត្រូវបានធ្វើបច្ចុប្បន្នភាព ដោយមានការពិគ្រោះយោបល់ ដែលសម្របសម្រួលដោយលេខាធិការដ្ឋាន CEPF កាលពីនៅចន្លោះខែឧសភា ឆ្នាំ ២០១៩ និងខែសីហាឆ្នាំ ២០២០។ មានអ្នកពាក់ព័ន្ធជាង១៧០ នាក់ ត្រូវបានពិគ្រោះ ក្នុងដំណើរការនៃការធ្វើបច្ចុប្បន្នភាពនេះ តាមរយៈសិក្ខាសាលា សារអេឡិចត្រូនិចឬការផ្តល់មតិយោបល់ដោយផ្ទាល់លើសេចក្តីព្រាងឯកសារស្ថានភាពប្រព័ន្ធអេកូឡូស៊ី។ មានអ្នកពាក់ព័ន្ធផ្សេងទៀត ក៏បានចូលរួមដោយប្រយោល តាមរយៈការផ្តល់នូវឯកសារយោងក្នុងការ ធ្វើបច្ចុប្បន្នភាពឯកសារស្ថានភាពប្រព័ន្ធអេកូឡូស៊ីនេះ។

## ការផ្តោតជាចំណុចស្នូលនៃការវនិយោគរបស់មូលនិធិ CEPF

ឯកសារស្ថានភាពប្រព័ន្ធអេកូឡូស៊ីនេះបង្ហាញពីទិដ្ឋភាពទូទៅនៃតំបន់ហតស្ពតឥណ្ឌូ-ភូមា សារសំខាន់នៃការអភិរក្សជីវចម្រុះនិងទិដ្ឋភាពសេដ្ឋកិច្ចសង្គម គោលនយោបាយនិងអង្គការសង្គមស៊ីវិល។ ឯកសារនេះបានបង្ហាញពីលទ្ធផលនៃការអភិរក្សលើប្រភេទ តំបន់ និងរបៀងជីវចម្រុះ និងការវាយតម្លៃពីកត្តាគម្រាមកំហែងដោយផ្ទាល់ចំបងចំពោះជីវចម្រុះនិងមូលហេតុ និងកត្តាបង្ក។ ការវិភាគស្ថានភាពប្រព័ន្ធអេកូឡូស៊ី បានបញ្ចប់ ដោយវាយតម្លៃការវិនិយោគអភិរក្សនាពេលថ្មីៗនេះនិងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុសម្រាប់ការអភិរក្សជីវចម្រុះ។

ឯកសារស្ថានភាពប្រព័ន្ធអេកូឡូស៊ីបានបន្តបង្កើតយុទ្ធសាស្ត្រវិនិយោគដ៏ធំមួយសម្រាប់ម្ចាស់ជំនួយដែលចាប់អារម្មណ៍ក្នុងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងអភិរក្សដោយអង្គការសង្គមស៊ីវិល។ យុទ្ធសាស្ត្រនេះមានបញ្ចូលការផ្តោតជាពិសេសនៃការវិនិយោគរបស់ CEPF ដែលអាចផ្តល់នូវគុណតម្លៃបន្ថែមដ៏ធំ។ មានន័យថា ការផ្តោតជាពិសេសនៃការវិនិយោគរបស់ CEPF គឺដើម្បីបង្ហាញពីអភិក្រមឆ្លើយតបទៅនឹងបញ្ហានានាដែលតំបន់ហតស្ពតកំពុងជួបប្រទះ (ឧទាហរណ៍៖ ការធ្វើពាណិជ្ជកម្មសត្វព្រៃខុសច្បាប់ ការអភិវឌ្ឍទំនប់វារីអគ្គិសនី ការពង្រីកដំណាំកសិកម្មឧស្សាហកម្មនិងការជីកយកថ្មកំបោរ) ដែលជួយបំពេញបន្ថែមដល់សមត្ថភាពអង្គការសង្គមស៊ីវិលហើយដែលអាចធ្វើទៅបាន។

មូលនិធិ CEPF នឹងពង្រឹងបន្ថែមទៀតលើបទពិសោធន៍ពីដំណាក់កាលវិនិយោគពីរដំបូង (២០០៨-២០១៣ និង២០១៣-២០២០) ដោយផ្តោតលើវិធីសាស្ត្រជោគជ័យនានា ដោយផ្លាស់ប្តូរពីគម្រោងសាកល្បងទៅជាអន្តរាគមន៍រយៈពេលវែងនិងសមាហរណកម្មលទ្ធផលកាន់តែស៊ីជម្រៅទៅក្នុងការអនុវត្តនៃគោលនយោបាយសាធារណៈនិងឯកជន។ ដោយទទួលស្គាល់ថា ការវិនិយោគ CEPF មិនអាចឆ្លើយតបទៅនឹងបញ្ហាអភិរក្សទាំងអស់ដែលកំពុងមាននៅ

ក្នុងតំបន់ហាតស្ពត មូលនិធិ CEPF ផ្តោតលើសកម្មភាពដែលអង្គការសង្គមស៊ីវិលអាចបន្ថែមតម្លៃបានយ៉ាងខ្ពស់បំផុត និងដោះស្រាយនូវគម្លាតនានាក្នុងការអភិរក្ស។

យុទ្ធសាស្ត្រវិនិយោគរួមគ្នាមានមហិច្ឆតានិងបានបង្ហាញពីទំហំនៃបញ្ហាអភិរក្សដែលតំបន់ហាតស្ពតឥណ្ឌូ - ភូមានៅតែប្រឈមនៅឡើយ។ ចំនួនធនធានដែលត្រូវការដើម្បីគាំទ្រដល់ការងារគ្រប់ផ្នែកនៃយុទ្ធសាស្ត្រក្នុងរយៈពេល៥ឆ្នាំខាងមុខទំនងជាលើសពីចំនួនធនធានដែលមានរបស់ម្ចាស់ជំនួយនីមួយៗសម្រាប់ការវិនិយោគដល់អង្គការសង្គមស៊ីវិល។ការអនុវត្តយុទ្ធសាស្ត្ររួមនេះ នឹងត្រូវសម្របសម្រួលតាមរយៈការប្រជុំជាទៀងទាត់រវាងមូលនិធិ CEPF និងអ្នកជំនួយទៃទៀតក្រោមការជួយគាំទ្រពីសហករណ៍នៃម្ចាស់ជំនួយសម្រាប់តំបន់មេគង្គក្រោម។ ដោយសារម្ចាស់ជំនួយផ្សេងទៀតត្រូវធ្វើការសម្រេចចិត្តអំពីការវិនិយោគនៅក្នុងតំបន់និងបង្កើតកម្មវិធីជំនួយរបស់ខ្លួន មូលនិធិ CEPF នឹងកែសម្រួលការបង្កើតកម្មវិធីផ្តល់មូលនិធិផ្ទាល់ខ្លួនដើម្បីចៀសវាងភាពស្ទួនគ្នា ក្នុងការដោះស្រាយគម្លាតនិងទាញយកប្រយោជន៍ពីឱកាសសម្រាប់កិច្ចសហការ ការសំយោគ បន្សីុនិងការពង្រីកបន្ថែម។

**អាទិភាពវិនិយោគផ្នែកជីវសាស្ត្រ**

មូលដ្ឋានផ្នែកជីវសាស្ត្រសម្រាប់ការវិនិយោគរបស់ CEPF នៅក្នុងតំបន់ហាតស្ពតឥណ្ឌូ-ភូមា ត្រូវបានផ្តល់ដោយលទ្ធផលនៃការអភិរក្សៈ សំណុំប្រភេទសត្វ ទីតាំងនិងរបៀង ត្រូវតែអភិរក្សដើម្បីទប់ស្កាត់ការបាត់បង់ជីវចម្រុះជាសាកល។ លទ្ធផលអភិរក្សសម្រាប់តំបន់ហាតស្ពតឥណ្ឌូ-ភូមាត្រូវបានកំណត់ក្នុងកំឡុងពេលរៀបចំឯកសារស្ថានភាពប្រពន្ធ័អេកូឡូស៊ីពីដំបូងនិងបន្ទាប់មកត្រូវបានធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ២០១១។ លទ្ធផលនៃការអភិរក្សត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីឆ្លុះបញ្ចាំងនូវព័ត៌មានថ្មីៗស្តីពីស្ថានភាពនៃប្រភេទ ទីតាំង និងរបៀងនៃការអភិរក្សជាដើម។ ដើម្បីឱ្យការវិនិយោគរបស់មូលនិធិ CEPFនិងម្ចាស់មូលនិធិផ្សេងទៀត ប្រកបដោយប្រសិទ្ធភាព លទ្ធផលអភិរក្សត្រូវបានផ្តល់អាទិភាពដោយប្រើលក្ខណៈវិនិច្ឆ័យស្តង់ដារ រួមទាំងភាពបន្ទាន់នៃសកម្មភាពអភិរក្សនិងឱកាសដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងអភិរក្សដែលមានស្រាប់។

បញ្ជីដែលបានបង្ហាញពីលទ្ធផលនៃប្រភេទសត្វបានកើនឡើងពី៧៥៥ ក្នុងឆ្នាំ ២០១១ ដល់ ១.២៩៨ ក្នុងឆ្នាំ ២០២០ ដែលបង្ហាញពីការកើនឡើងនូវចំនួនប្រភេទសត្វដែលរងការគម្រាមកំហែងជាសកល ក្នុងបញ្ជីក្រហមរបស់អង្គការ IUCN។ ប្រភេទដែលមានការកើនឡើងខ្លាំងបំផុតគឺជាប្រភេទសត្វល្មូននិងត្រី ដែលការវាយតម្លៃនៅលើបញ្ជីក្រហម ត្រូវបានបញ្ចប់។ បញ្ជីដែលបានបង្ហាញពីលទ្ធផលនៃតំបន់ជីវចម្រុះ បានកើនឡើងពី ៥០៩ ដល់ ៥៥៥ កន្លែងដែលឆ្លុះបញ្ចាំងពីការកំណត់ទីតាំងតំបន់KBA ថ្មីៗថែមទៀត រួមទាំងប្រព័ន្ធអេកូឡូស៊ីទឹកសាបនៅក្នុងអាងទន្លេមេគង្គនិងអេកូឡូស៊ីតំបន់ថ្មកំបោរនៅប្រទេសមីយ៉ាន់ម៉ា។ លទ្ធផលនៃតំបន់ជីវចម្រុះទាំង ៥៥៥ កន្លែងនេះ គ្របដណ្តប់លើផ្ទៃដីសរុបប្រមាណ ៣៩០.០០០ គីឡូម៉ែត្រក្រឡាឬស្មើនឹង ១៦ ភាគរយនៃផ្ទៃដីសរុប (២,៣ លានគីឡូម៉ែត្រការ៉េ)

នៃតំបន់ហាតស្គតទាំងមូល។ បញ្ជីលទ្ធផលនៃរបៀងជីវចម្រុះនៅមានស្ថេរភាព ដោយនៅមាន ៦៥ កន្លែងនៅឆ្នាំ ២០២០ ហើយនៅឆ្នាំ ២០១១ មាន ៦៦កន្លែង។

លទ្ធផលបង្ហាញពីរបៀងជីវចម្រុះចំនួន ៥កន្លែង ត្រូវបានផ្តល់អាទិភាពសម្រាប់ការវិនិយោគអភិរក្ស។ វាមានសរុបចំនួន ៦៦កន្លែង ដែលត្រូវបានជ្រើសរើសដោយស្វ័យប្រវត្តិជាតំបន់អាទិភាព។ បន្ថែមលើរបៀងជីវចម្រុះទាំង៦ មានបណ្តុំតំបន់ជីវចម្រុះសំខាន់ៗនៃតំបន់ថ្មកំបោរចំនួន២៤កន្លែង នៅមីយ៉ាន់ម៉ា ត្រូវបានកំណត់ថាជាភូមិសាស្ត្រអាទិភាពសម្រាប់ការវិនិយោគ។ របៀងជីវចម្រុះទាំង ៥ និងបណ្តុំតំបន់ជីវចម្រុះសំខាន់ៗនៃតំបន់ថ្មកំបោរ មានទំហំសរុប ១២០.៦២៣ ហិកតា ស្មើនឹង ៥ ភាគរយនៃផ្ទៃដីសរុបនៃតំបន់ហាតស្គតនេះ។ តួលេខនេះបង្ហាញពីការថយចុះយ៉ាងច្រើននូវទំហំរបៀងជីវចម្រុះនៃភូមិសាស្ត្រជាអាទិភាព ដែលបានគូសបញ្ជាក់ក្នុងឯកសារស្ថានភាពប្រព័ន្ធអេកូឡូស៊ីឆ្នាំ ២០១១ ដែលមានផ្ទៃដី ៧៨៦.៥៥១ ហិកតាឬ ៣៤ ភាគរយនៃតំបន់ហាតស្គត។

នេះដោយសារតែការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងនៃអាទិភាពភូមិសាស្ត្រ នៅក្នុងប្រទេសមីយ៉ាន់ម៉ាពីប្រទេសទាំងមូលរហូតដល់ច្រករបៀងមួយនិងបណ្តាញនៃតំបន់មួយ។ របៀងជីវចម្រុះនៃតំបន់ជួរភ្នំហៃណានលែងជាតំបន់អាទិភាពហើយត្រូវបានជំនួសដោយរបៀងព្រៃលិចទឹកតាមរដូវកាលភាគខាងជើងដែលមានទំហំប្រហាក់ប្រហែលគ្នា។

បើនិយាយពីអាទិភាពសតិវិទ្យាសម្រាប់ការវិនិយោគ ប្រភេទសត្វឆ្អឹងខ្នងដែលត្រូវបានគំរាមកំហែងជាសាកល ចំនួន១៣៦ ត្រូវបានជ្រើសរើសជាប្រភេទអាទិភាព។ ទាំងនេះរួមមានសត្វល្មូនចំនួន ៣៩ ថនិកសត្វ ៣៤ ត្រី ៣១ និងបក្សី ២៧ ប៉ុន្តែថលជលិកសត្វមានតែ ៥ តែប៉ុណ្ណោះ ដែលបញ្ជាក់ថាប្រភេទថលជលិកសត្វ តម្រូវឱ្យមានសកម្មភាពអភិរក្សពិសេសជាក់លាក់ ដែលផ្តោតជាពិសេសលើតែប្រភេទសត្វនេះតែប៉ុណ្ណោះ។ ប្រភេទសត្វដែលមានអាទិភាពរួមមានអណ្តើកចំនួន២៨ ពានរចំនួន១៥ និងប្រភេទថនិកសត្វដែលមានក្រចកជើងចំនួន១០ ដែលឆ្លុះបញ្ចាំងពីមានសកម្មភាពគម្រាមកំហែងខ្ពស់លើប្រភេទក្រុមទាំងនេះដោយសារការធ្វើអាជីវកម្មហួសកម្រិត ដែលភាគច្រើនដោយសារតម្រូវការពីការជួញដូរសត្វព្រៃខុសច្បាប់។

## របៀបអាទិភាពសម្រាប់ការវិនិយោគរបស់មូលនិធិ CEPF នៅតំបន់ហតស្តតឥណ្ឌូភូមា




**កំណត់សំគាល់៖** តំបន់ភ្នំថ្មកំបោរនៅប្រទេសមីយ៉ាន់ម៉ាមិនបានបង្ហាញនៅលើផែនទីនេះទេ ដោយសារតំបន់ទាំងនោះតូចៗពេកក្នុងការរំលេចនៅលើផែនទីនេះ។

បញ្ជីនៃប្រភេទអាទិភាពបានបង្ហាញពីការថយចុះពីចំនួនប្រភេទអាទិភាព១៥២ ដែលកំណត់ឯកសារស្ថានភាពប្រព័ន្ធអេកូឡូស៊ី ឆ្នាំ ២០១១។ នេះដោយសារតែបទពិសោធន៍ពីដំណាក់កាលនៃវិនិយោគមុនដែលផ្តល់អាទិភាពផ្តោតលើតែប្រភេទសត្វតែមួយមិនមែនជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធិភាពដើម្បីឲ្យមានការចូលរួមពីអង្គការសង្គមស៊ីវិលក្នុងសកម្មភាពអភិរក្សប្រភេទរុក្ខជាតិដែលរងការគម្រាមកំហែងជាសាកលក្នុងតំបន់ហតស្តតឥណ្ឌូ-ភូមា។ សម្រាប់

ដំណាក់កាលថ្មីនេះ មូលនិធិCEPF នឹងផ្តោតលើការអភិរក្សផ្អែកលើតំបន់ ដោយប្រកាន់យកអភិក្រមអេកូឡូស៊ីដែលទំនងជាយុទ្ធសាស្ត្រមានប្រសិទ្ធភាពជាងមុនសម្រាប់ការអភិរក្សរុក្ខជាតិ។

**អាទិភាពសម្រាប់ការវិនិយោគ**

អាទិភាពសម្រាប់ការវិនិយោគអភិរក្សក្នុងតំបន់ហតស្តត ត្រូវបានកំណត់តាមរយៈដំណើរការនៃការពិគ្រោះយោបល់ជាមួយអ្នកភាគីពាក់ព័ន្ធ ដោយផ្អែកលើការវិភាគពីការគម្រាមកំហែងសំខាន់ៗចំពោះជីវចម្រុះនៅក្នុងតំបន់ហតស្តតនិងមូលហេតុរបស់វា។ ចំណាត់ថ្នាក់នៃការគំរាមកំហែង មិនបានផ្លាស់ប្តូរច្រើនទេ ធៀបនឹងចំណាត់ថ្នាក់ពីការពិគ្រោះយោបល់ជាមួយអ្នកភាគីពាក់ព័ន្ធក្នុងកំឡុងពេលធ្វើបច្ចុប្បន្នភាពនៃស្ថានភាពប្រព័ន្ធអេកូឡូស៊ីឆ្នាំ ២០១១។ ការធ្វើបច្ចុប្បន្នទាំងពីរលើកនេះ មានបង្ហាញពីកត្តាគម្រាមកំហែងចំបងៗជាច្រើន រួមមាន ការប្រមាញ់ ការធ្វើពាណិជ្ជកម្ម ការបរិភោគសាច់សត្វព្រៃ និងដំណាំកសិឧស្សាហកម្ម។ ហេដ្ឋារចនាសម្ព័ន្ធធំៗ ជាប់ចំណាត់ថ្នាក់លេខ៣។ ក្នុងឆ្នាំ ២០១១ ការគម្រាមកំហែងមានតែទំនប់វារីអគ្គិសនីទេ តែនៅឆ្នាំ២០១៩ វាមានទាំងហេដ្ឋារចនាសម្ព័ន្ធធំៗ (ទំនប់វារីអគ្គិសនី ផ្លូវថ្នល់ កំពង់ផែ។ ល។ ) ដែលឆ្លុះបញ្ចាំងពីផលប៉ះពាល់ដែលមិនមានតែគម្រោងវារីអគ្គិសនីធំ ៗ ប៉ុណ្ណោះទេ វាមានទាំងផលប៉ះពាល់ពីការធ្វើផ្លូវថ្នល់ ការធ្វើនាវាចរណ៍តាមដងទន្លេ ការសង់បង្គោលបញ្ជូនចរន្តអគ្គិសនី និងហេដ្ឋារចនាសម្ព័ន្ធ។ផ្សេងៗទៀត។ ក្នុងការធ្វើបច្ចុប្បន្នទាំងពីរលើកនេះ មានការគម្រាមកំហែងខ្លាំងបំផុតចំនួន ៥បន្ទាប់ រួមមានការកាប់ឈើ ការពង្រីងនិងការពង្រីកកសិកម្មខ្នាតតូចនិងការផ្លាស់ប្តូរអាកាសធាតុ។ ទាំងនេះអាចត្រូវបានចាត់ទុកថាជាការគម្រាមកំហែងដ៏ធ្ងន់ធ្ងរ។

ដើម្បីឆ្លើយតបទៅនឹងការគម្រាមកំហែងទាំងនេះនិងការគម្រាមកំហែងផ្សេងទៀតនិងដើម្បីចាប់ផ្តើមដោះស្រាយមូលហេតុមួយចំនួននោះ យុទ្ធសាស្ត្រវិនិយោគរយៈពេល ៥ ឆ្នាំត្រូវបានធ្វើបច្ចុប្បន្នភាព។ ទិសដៅយុទ្ធសាស្ត្រទាំង ១១ នៅដដែល ដោយមានការកែប្រែសម្រួលមួយចំនួន។ ឧទាហរណ៍ទិសដៅយុទ្ធសាស្ត្រទី២ ស្តីពីការធ្វើពាណិជ្ជកម្មសត្វព្រៃខុសច្បាប់ត្រូវបានកែសម្រួល ដើម្បីឆ្លុះបញ្ចាំងពីការចូលរួមចំណែកជាពិសេសដែលការវិនិយោគលើទិសដៅយុទ្ធសាស្ត្រមួយនេះ អាចកាត់បន្ថយហានិភ័យនៃការកើតមានឡើងនូវជម្ងឺសត្វព្រៃ។ តារាងបង្ហាញពីអាទិភាពនៃការវិនិយោគចំនួន៣៨ ដែលមានក្នុងឯកសារស្ថានភាពប្រពន្ធ័អេកូឡូស៊ីឆ្នាំ២០១១ ត្រូវបានបន្ថែមដល់ចំនួន៤៥ ដោយផ្អែកលើបទពិសោធន៍របស់អ្នកពាក់ព័ន្ធស្តីពីថាតើអភិក្រមការអភិរក្សណាខ្លះ ដែលមានប្រសិទ្ធភាពបំផុត និងបានបញ្ចូលនូវមេរៀនជាបទពិសោធន៍ពីដំណាក់កាលមុន។ ក្នុងចំណោមទិសដៅយុទ្ធសាស្ត្រទាំង ១១ ក្នុងយុទ្ធសាស្ត្រទាំងមូល មានទិសដៅយុទ្ធសាស្ត្រចំនួន ៦ ត្រូវបានបញ្ចូលទៅក្នុងការចំណុចស្នូលនៃការវិនិយោគរបស់ CEPF ។ ទិសដៅយុទ្ធសាស្ត្រទាំង ៦ នេះមានអាទិភាពវិនិយោគចំនួន ២៣ ក្នុងចំណោមអាទិភាពវិនិយោគទាំង ៤៥ នៅក្នុងយុទ្ធសាស្ត្រទាំងមូលដោយផ្តោតលើទិសដៅណាដែលឆ្លើយតបភាពខ្លាំងនៃមូលនិធិនិងចូលរួមចំណែកដោយ

ផ្ទាល់ដល់គោលបំណងសកលរបស់ខ្លួននិងក្នុងពេលជាមួយគ្នានឹងនោះដែរបាន បំពេញបន្ថែមដល់យុទ្ធសាស្ត្រវិនិយោគនៃម្ចាស់ជំនួយផ្សេងទៀត។

**ទិសដៅយុទ្ធសាស្ត្រ និង អាទិភាពនៃការវិនិយោគនៅក្នុងតំបន់ឥណ្ឌូ - ភូមា**

| ទិសដៅយុទ្ធសាស្ត្រ | អាទិភាពនៃការវិនិយោគ |
|---|---|
| **សមាសធាតុ ១៖ ការអភិរក្សប្រភេទអាទិភាព** | |
| **១.ការពារប្រភេទដែលរងការគម្រាមកំហែងជាសកលជាអាទិភាព ដោយកាត់បន្ថយការគម្រាមកំហែងចំបង [ចំណុចស្នូលCEPF]** | ១.១ ទ្រទ្រង់កម្មវិធីអភិរក្សរយៈពេលវែងសម្រាប់ប្រភេទស្នូលនៃប្រភេទជាអាទិភាព |
| | ១.២ ស្តារនូវចំនួននៃប្រភេទសត្វព្រៃជាអាទិភាពដែលអាចរស់នៅបានស្របតាមគោលការណ៍ណែនាំសកល |
| | ១.៣ ស្រាវជ្រាវប្រភេទសត្វដែលរងការគម្រាមកំហែងជាសកល ដើម្បីបង្កើតឲ្យមានទិន្នន័យ ឬព័ត៌មានស្តីពីស្ថានភាព និងរបាយរស់នៅ |
| | ១.៤ ស្រាវជ្រាវ និងសាកល្បងប្រភពមូលនិធិដែលមានលក្ខណៈនវានុវត្តន៍សម្រាប់ការអភិរក្សប្រភេទ |
| | ១.៥ គាំទ្រដល់បុគ្គលិកផ្តើមខាងការពារសត្វព្រៃនៅកម្រិតថ្នាក់សហគមន៍ ដើម្បីអនុវត្តសកម្មភាពមូលដ្ឋានសម្រាប់ប្រភេទសត្វអាទិភាព |
| **២. កាត់បន្ថយហានីភ័យនៃការកើតឡើងនូវជម្ងឺសត្វព្រៃ ដោយកាត់បន្ថយការជួញដូរខុសច្បាប់ បរិភោគសាច់សត្វព្រៃ និង ការគម្រាមកំហែងផ្សេងៗ [ចំណុចស្នូលCEPF]** | ២.១ គាំទ្រភ្នាក់ងារអនុវត្តច្បាប់ ដើម្បីលាតត្រដាញការជួញដូរសត្វព្រៃដែលមានលក្ខណៈជាបណ្តាញ ដោយលើកកម្ពស់ការអនុវត្តល្អបំផុតជាសកលជាមួយការស៊ើបអង្កេត ការស៊ើបការណ៍ចារកម្ម និងអ្នករាយការណ៍ |
| | ២.២ សម្របសម្រួលកិច្ចសហការក្នុងចំណោមភ្នាក់ងារអនុវត្តច្បាប់ដែលចូលរួមក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរសត្វព្រៃខុសច្បាប់ ព្រមទាំងវិស័យដទៃទៀតដែលជាផ្នែកនៃវិធីសាស្ត្រសុខភាពតែមួយ |
| | ២.៣ ធ្វើការជាមួយក្រុមហ៊ុនឯកជន និងរដ្ឋ ដែលផ្តោតជាពិសេសលើផ្នែកភស្តុភារ និងវេទិកាអនឡាញ ដើម្បីកាត់បន្ថយការពាក់ព័ន្ធរបស់ពួកគេក្នុងការជួញដូរសត្វព្រៃ |

| | |
|---|---|
| | ២.៤ គាំទ្រដល់យុទ្ធនាការតាមគោលដៅ ដើម្បីកាត់បន្ថយតម្រូវការ និងប្រមូលការចូលរួមជាសាធារណៈក្នុងការតាមដានស្វែងរក និងរាយការណ៍អំពីឧក្រិដ្ឋកម្មសត្វព្រៃ |
| | ២.៥ ស្វែងយល់ និងគាំទ្រសកម្មភាពដែលពាក់ព័ន្ធនឹងការផ្សារភ្ជាប់គ្នារវាងជីវចម្រុះ និងសុខភាពមនុស្ស រួមទាំងតួនាទីនៃការបាត់បង់ជីវចម្រុះដែលនាំឲ្យមានការកើតមានឡើងនូវជម្ងឺសត្វព្រៃ |
| **សមាសធាតុ ២៖ ការការពារ និង ការគ្រប់គ្រងតំបន់អាទិភាព** | |
| **៣. ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងនៅតំបន់ការពារឲ្យក្លាយជាឧបករណ៍សម្រាប់អភិរក្សតំបន់អាទិភាព** | ៣.១ គាំទ្រឲ្យមានការប្រើប្រាស់ស្តង់ដារសកល និងឧបករណ៍សម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដោយ អ្នកពាក់ព័ន្ធទាំងអស់ និងដាក់ចូលទៅក្នុងគោលនយោបាយជាតិ |
| | ៣.២ បង្កើតកម្មវិធីបណ្តុះបណ្តាលដែលមានការទទួលស្គាល់សម្រាប់ប្រតិបត្តិករតំបន់ការពារធម្មជាតិក្នុងស្ថាប័នសិក្សាក្នុងស្រុក និង ស្ថាប័នផ្សេងទៀត |
| | ៣.៣ សាកល្បងឱ្យមានការចូលរួមដោយផ្ទាល់ពីអង្គការសង្គមស៊ីវិលក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងចងក្រងជាឯកសារនូវការអនុវត្តល្អៗ |
| | ៣.៤ គាំទ្រដល់ការប្រើប្រាស់លទ្ធផលនៃស្តង់ដារសកល និងឧបករណ៍សម្រាប់ការគ្រប់គ្រង តំបន់ការពារធម្មជាតិដែលបានកែសម្រួល និងរៀបចំថវិកា |
| **៤. ផ្តល់សិទ្ធិអំណាចដល់សហគមន៍មូលដ្ឋាន ដើម្បីចូលរួមក្នុងការអភិរក្ស និងគ្រប់គ្រងតំបន់អាទិភាព [ចំណុចស្នូលCEPF]** | ៤.១ គាំទ្រសហគមន៍វិភាគបញ្ហាអភិរក្ស និង ផ្សព្វផ្សាយដល់ពួកគេអំពីសិទ្ធិ និងឱកាស ទាក់ទងទៅនឹងការគ្រប់គ្រង និង អភិរក្សធនធានធម្មជាតិ |
| | ៤.២ សាកល្បង ពង្រីក និង បង្កើតយន្តការនិរន្តរភាព សម្រាប់សហគមន៍ព្រៃឈើ សហគមន៍នេសាទ និងតំបន់ការពារធម្មជាតិ ដែលគ្រប់គ្រងដោយសហគមន៍ តាមរយៈដំណើរការជាក់ស្តែងដែលដឹកនាំដោយសហគមន៍ |
| | ៤.៣ បង្កើតយន្តការសហគ្រប់គ្រងសម្រាប់តំបន់ការពារធម្មជាតិដែលអាចឱ្យសហគមន៍ចូលរួមក្នុងការកំណត់តំបន់ ការគ្រប់គ្រង និង អភិបាលកិច្ច |

| | |
|---|---|
| | ៤.៤ ពិនិត្យឡើងវិញនូវការកំណត់អត្តសញ្ញាណនៃតំបន់ KBA នៅក្នុងតំបន់ហាតស្ពត ដោយប្រើបទដ្ឋាន KBA ថ្មី |
| | ៤.៥ វាយតម្លៃដោយភាគីទីពអំពីឥទ្ធិពលនៃគម្រោងនៅក្នុងតំបន់អាទិភាព |
| **៥. ពង្រឹងការអភិរក្សជីវៈចម្រុះដោយលើកកម្ពស់ជីវភាពរស់នៅប្រកបដោយចីរភាព និង ការលើកទឹកចិត្តដល់សហគមន៍មូលដ្ឋាននៅតាមតំបន់អាទិភាព** | ៥.១ លើកកម្ពស់គម្រោងជីវភាពរស់នៅប្រកបដោយចីរភាព ដែលផ្សារភ្ជាប់ការកែលម្អជីវភាពរស់នៅ និង សេដ្ឋកិច្ចសង្គម ទៅនឹងលទ្ធផលអភិរក្ស នៅតាមតំបន់អាទិភាព និងចងក្រងឯកសារ និងចែករំលែកការអនុវត្ត និងមេរៀនដែលទទួលបាន |
| | ៥.២ បង្កើត និង ពង្រឹងការផ្តួចផ្តើមគំនិតអេកូទេសចរណ៍ដែលមានលក្ខណៈជាគំរូល្អ នៅតាមតំបន់អាទិភាព |
| **សមាសធាតុ ៣៖ ការបង្កើនភាពតភ្ជាប់ផ្នែកអេកូឡូស៊ី និងភាពធន់** | |
| **៦. បង្ហាញអភិក្រមនានាដើម្បីបញ្ចូលសេវាកម្មជីវៈចម្រុះ និង ប្រព័ន្ធអេកូឡូស៊ីនៅក្នុងផែនការអភិវឌ្ឍនៅក្នុង របៀងជីវចម្រុះអាទិភាព [ចំណុចស្នូលCEPF]** | ៦.១ វិភាគគោលនយោបាយ ផែនការ និងកម្មវិធីអភិវឌ្ឍន៍; វាយតម្លៃពីឥទ្ធិពលរបស់វាទៅលើសេវាកម្មជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី និងស្នើ ព្រមទាំងគាំទ្រយ៉ាងសកម្មដល់ការអនុវត្តសេណារីយ៉ូនៃការអភិវឌ្ឍជាជម្រើស ដំណោះស្រាយដោយផ្អែកលើធម្មជាតិ និងវិធានការកាត់បន្ថយនានា។ |
| | ៦.២ បង្កើតគម្រោងដែលជាគំរូបង្ហាញ សម្រាប់ការស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីដោយមានពិធីសារសមស្របសម្រាប់ងាយស្រួលក្នុងការចម្លងអនុវត្តតាម |
| | ៦.៣ ធ្វើឱ្យប្រព័ន្ធផ្សព្វផ្សាយមានការចូលរួម ដើម្បីបង្កើនការយល់ដឹង ជូនដំណឹងអំពីការជជែកវែកញែកជាសាធារណៈ និង ការសម្រេចចិត្តដែលមានឥទ្ធិពលលើការបញ្ជ្រាបជីវៈចម្រុះទៅក្នុងផែនការអភិវឌ្ឍ |
| | ៦.៤ សាកល្បង និងពង្រីកគំរូសម្រាប់ផលិតកម្មមេត្រីភាពជាមួយនឹងជីវៈចម្រុះរួមមានការបញ្ជាក់ និងការដាក់ស្លាកសញ្ញាបរិស្ថាន |

| | |
|---|---|
| **៧. កាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់សង្គម និងបរិស្ថាននៃការធ្វើដំណាំកសិ-ឧស្សាហកម្មនិង ទំនប់វារីអគ្គិសនីនៅតាមរបៀងអាទិភាព** | ៧.១ គាំទ្រដល់ការចុះបញ្ជីដីធ្លីសម្រាប់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចនៅតាមតំបន់អាទិភាព |
| | ៧.២ រៀបចំឲ្យមានការទទួលស្គាល់ផ្លូវច្បាប់ចំពោះតំបន់អាទិភាពដែលមិនទាន់មានការការពារ ដែលរងផលប៉ះពាល់ដោយការប្រើប្រាស់ដីធ្លីមិនសមស្រប |
| | ៧.៣ ពង្រឹងសំលេងសហគមន៍ ដែលរងផលប៉ះពាល់ដោយសារការធ្វើកសិឧស្សាហកម្ម និងទំនប់វារីអគ្គិសនី |
| | ៧.៤ ធ្វើការជាមួយវិស័យឯកជន ដើម្បីធានាថាចម្ការកសិ- ឧស្សាហកម្ម និងទំនប់វារីអគ្គិសនីត្រូវបានអភិវឌ្ឍ និង ដំណើរការប្រកបដោយលក្ខណៈទំនួលខុសត្រូវផ្នែកបរិស្ថាន និងសង្គម។ |
| | ៧.៥ កំណត់នូវគំរូនៃភាពប្រទ្បាក់ក្រទ្បាគ្នារវាងទឹក ចំណីអាហារ និងថាមពល ហើយបង្កើតឲ្យមានជាជម្រើសគោលនយោបាយ |
| | ៧.៦ គាំទ្រការស្រាវជ្រាវ និងការតាមដានពិនិត្យនៃផលប៉ះពាល់នៃការធ្វើដំណាំកសិ-ឧស្សាហកម្ម និង ទំនប់វារីអគ្គិសនី |
| **សមាសធាតុ ៤៖ ការអភិវឌ្ឍស្ថាប័នអភិរក្ស** | |
| **៨. ពង្រឹងសមត្ថភាពសង្គមស៊ីវិល ដើម្បីធ្វើការលើជីវៈចម្រុះ សហគមន៍ និង ជីវភាពរស់នៅនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន** **[ចំណុចស្នូលCEPF]** | ៨.១ គាំទ្រដល់យន្តការជាបណ្តាញដែលជំរុញឱ្យមានការឆ្លើយតបជារួមរបស់អង្គការសង្គមស៊ីវិល ទៅនឹងអាទិភាព និង ការគំរាមកំហែងដែលលេចឡើង |
| | ៨.២ ផ្តល់ការគាំទ្រជាស្នូលសម្រាប់ការកសាងសមត្ថភាពបច្ចេកទេស និងស្ថាប័នប្រកបដោយចីរភាពដល់អង្គការសង្គមស៊ីវិលក្នុងស្រុក |
| | ៨.៣ បង្កើតឲ្យមានយន្តការផ្សារភ្ជាប់អ្នកស្ម័គ្រចិត្តទៅនឹងការបំពេញតម្រូវការបណ្តុះបណ្តាលរបស់អង្គការសង្គមស៊ីវិល |

| | |
|---|---|
| **៩. ធ្វើការអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងចំគោលដៅ ដើម្បីកសាងសមត្ថភាព និ គាំទ្រដល់ការអភិរក្សជីវៈចម្រុះនៅក្នុងគ្រប់ផ្នែកទាំងអស់ក្នុងសង្គម** | ៩.១ វិនិយោគលើការអភិវឌ្ឍវិជ្ជាជីវៈរបស់អ្នកដឹកនាំអភិរក្សនាពេលអនាគតតាមរយៈការគាំទ្រកម្មវិធីការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ វិញ្ញាបនបត្រ វិញ្ញាបនបត្រមធ្យមសិក្សា និងថ្នាក់បរិញ្ញាបត្រ នៅស្ថាប័នសិក្សាក្នុងស្រុក និងលើកកម្ពស់ការអនុវត្តចម្លងតាមក្នុងថ្នាក់តំបន់ ទៅដល់បណ្តាប្រទេសនីមួយៗផ្សេងទៀត។ |
| | ៩.២ សិក្សាពីលទ្ធភាពនៃការបង្កើតមជ្ឈមណ្ឌលសិក្សាផ្នែកអភិរក្សនៅតំបន់ឥណ្ឌា-ភូមា |
| | ៩.៣ ជំរុញភាពជាអ្នកដឹកនាំ ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការវិនិយោគក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈដល់បុគ្គលសំខាន់ៗ |
| | ៩.៤ អនុវត្តកម្មវិធីអប់រំពិសោធន៍ ដើម្បីផ្សារភ្ជាប់កុមារនៅតាមសាលារៀនទៅនឹងធម្មជាតិនៅតំបន់របៀងជីវចម្រុះអាទិភាព និងហួសពីតំបន់នេះទៅទៀត |
| | ៩.៥ ផ្សព្វផ្សាយ និងការលើកកម្ពស់ការយល់ដឹងប្រកបដោយប្រសិទ្ធភាព និងចំគោលដៅ ដើម្បីឲ្យមានការផ្លាស់ប្តូរអាកប្បកិរិយា ក្នុងចំណោមប្រជាជននៅតាមជនបទ និងតាមទីប្រជុំជនទាក់ទងនឹងគុណតម្លៃនៃប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ដោយផ្តោតលើជីវភាពរស់នៅ របៀបរបបនៃការហូបចុក និងរបៀបរស់នៅ |
| | ៩.៦ បណ្តុះបណ្តាល និងផ្សព្វផ្សាយឲ្យចំគោលដៅ ដល់អ្នកធ្វើការសម្រេចចិត្តក្នុងជួររដ្ឋាភិបាល និង វិស័យឯកជន លើការអភិរក្សជីវៈចម្រុះ រួមបញ្ចូលទាំងផលប៉ះពាល់នៃគោលនយោបាយ និង គម្រោងអភិវឌ្ឍន៍លើប្រព័ន្ធអេកូឡូស៊ី។ |
| **សមាសធាតុ ៥៖ ការសម្របសម្រួល និងការតាមដានពិនិត្យការវិនិយោគអភិរក្ស** | |
| **១០. វាយតម្លៃឥទ្ធិពលនៃការវិនិយោគអភិរក្សលើជីវៈចម្រុះ និងសុខុមាលភាពមនុស្ស តាមរយៈការតាមដានពិនិត្យជាប្រព័ន្ធ** | ១០.១ បង្កើតបទដ្ឋាន និងប្រព័ន្ធរួម សម្រាប់តាមដានពិនិត្យផលប៉ះពាល់ និងប្រសិទ្ធភាពនៃសកម្មភាពអភិរក្ស |
| | ១០.២ បង្កើតបទដ្ឋាន និងប្រព័ន្ធរួម សម្រាប់តាមដានពិនិត្យផលប៉ះពាល់អវិជ្ជមាននៃគោលនយោបាយ ផែនការ និង សកម្មភាពអភិវឌ្ឍន៍នានាគ្រប់ពហុកម្រិតទាំងអស់ |

| | |
|---|---|
| | ១០.៣ គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងជាប្រព័ន្ធ ដើម្បីកសាងសមត្ថភាពក្នុងការតាមដានពិនិត្យ និងវិភាគទិន្នន័យក្នុងចំណោមអង្គការក្នុងស្រុក |
| | ១០.៤ បង្កើត និងសាកល្បងយន្តការ ដើម្បីធានាថាលទ្ធផលនៃការពិនិត្យតាមដាន បានផ្តល់ព័ត៌មានដល់ការជជែកវែកញែកគោលនយោបាយជាតិ និងការគ្រប់គ្រងកែសម្រួលតាមមូលដ្ឋាន |
| **១១. ផ្តល់ការដឹកនាំជាយុទ្ធសាស្ត្រ និងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពលើការវិនិយោគអភិរក្សតាមរយៈក្រុមការងារគ្រប់គ្រងមូលនិធិថ្នាក់តំបន់** | ១១.១ បង្កើតក្រុមនៃអង្គការសង្គមស៊ីវិល ដែលធ្វើការនៅកម្រិតស្ថាប័ន និងនយោបាយ ឆ្ពោះទៅរកការសម្រេចគោលដៅអភិរក្សរួម ដែលបានដាក់ចេញនៅក្នុងឯកសារស្ថានភាពប្រព័ន្ធអេកូឡូស៊ី |

## សេចក្តីសន្និដ្ឋាន

ទាក់ទងនឹងភាពចម្រុះនៃប្រភេទសត្វនិងប្រភេទដែលមានតែក្នុងតំបន់ (Endenism) តំបន់ឥណ្ឌូ-ភូមាគឺជាតំបន់មួយដែលមានសារៈសំខាន់ខាងជីវសាស្ត្របំផុតនៅលើភពផែនដី។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយការវិនិយោគអភិរក្សពីប្រភពអន្តរជាតិមានចំនួនយ៉ាងតិច១៦០លានដុល្លារក្នុងមួយឆ្នាំ។ ទោះបីជាការបូកសរុបដែលបានវិនិយោគកម្រិតគាំទ្រទូទៅសម្រាប់ការអភិរក្សក្នុងតំបន់ហតស្ពតពីរដ្ឋាភិបាលវិស័យឯកជន និងម្ចាស់ជំនួយអន្តរជាតិមិនគ្រប់គ្រាន់ដើម្បីដោះស្រាយការគម្រាមកំហែងដ៏ធំនិងយ៉ាងលឿនដល់ធនធានជីវៈចម្រុះក៏ដោយជាពិសេសកសិឧស្សាហកម្ម ការបរបាញ់ ការធ្វើពាណិជ្ជកម្មនិងការបរិភោគសាច់សត្វព្រៃ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធធំៗនិងការកាប់ឈើ។ ឬសគល់នៃបញ្ហានិងកត្តាបង្កឱ្យមានការបាត់បង់ជីវៈចម្រុះរួមមានកំណើនប្រជាជន ការធ្វើនគរូបនីយកម្ម ការចំណាកស្រុក កំណើនសេដ្ឋកិច្ចនិងការកើនឡើងនូវការប្រើប្រាស់ធនធាន ការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ក្របខ័ណ្ឌបទប្បញ្ញត្តិនិងអភិបាលកិច្ចនៅទាន់ខ្សោយនិងគំរូនៃការអភិវឌ្ឍន៍ដែលផ្តល់អាទិភាពដល់គម្រោងខ្នាតធំដោយមិនមានតម្លាភាពគ្រប់គ្រាន់ឬការចូលរួមពីសាធារណៈជន។

ប្រសិនបើការគម្រាមកំហែងទាំងនេះនៅតែបន្តឥតឈប់ឈរ ប្រព័ន្ធអេកូឡូស៊ីធម្មជាតិនៅតំបន់ហតស្ពតនឹងបន្តរិចរលនិងបាត់បង់ សមត្ថភាពក្នុងការផ្តល់សេវាប្រព័ន្ធអេកូឡូស៊ីនឹងរិចរល ភាពធន់នៃតំបន់ទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនឹងថយចុះ អត្រានៃការផុតពូជប្រភេទសត្វនឹងកើនឡើង និងហានិភ័យនៃការកើតមានឡើងនៃជម្ងឺសត្វព្រៃនឹងកើនឡើង។ អង្គការសង្គមស៊ីវិលជាតួអង្គដ៏សំខាន់ដើម្បីដោះស្រាយទាំងការគំរាមកំហែងនៅចំពោះមុខចំពោះជីវចម្រុះនិងមូលហេតុទាំងនោះ។ ទោះយ៉ាងណាក៏ដោយការវិនិយោគនាពេលបច្ចុប្បន្ន មិនគ្រាន់

តែផ្តោតលើអាទិភាពខ្ពស់បំផុតនៃការអភិរក្សឬលើកកម្ពស់វិធីសាស្ត្រដែលមានប្រសិទ្ធិភាពបំផុតនោះទេ តែគឺជាសក្តានុពលឲ្យមានការចូលរួមពីសង្គមស៊ីវិលក្នុងការអភិរក្សជីវៈចម្រុះ។ នៅក្នុងបរិបទនេះឱកាសសម្រាប់មូលនិធិស៊ី CEPF និងម្ចាស់មូលនិធិដទៃទៀតដើម្បីគាំទ្រដល់ការអភិរក្សជីវៈចម្រុះនៅក្នុងតំបន់ក្តៅគឺស្ទើរតែគ្មានកំណត់។